# គាំទ្រការរៀនសូត្រសកម្ម COVID

## ព័ត៌មានសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ

### អំពីកម្មវិធីគាំទ្រការរៀនសូត្រសកម្ម COVID

កម្មវិធីគាំទ្រការរៀនសូត្រសកម្ម COVID (COVID Intensive Learning Support Program (CILSP)) ផ្ដល់ជូនការបង្រៀនអប់រំជាក្រុមតូច សម្រាប់សិស្សដែលត្រូវការវាច្រើនបំផុត នៅទូទាំងសាលាបឋមសិក្សា វិទ្យាល័យ និងសាលាឯកទេសរដ្ឋ NSW។

កម្មវិធីនេះគឺជាកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួងអប់រំរដ្ឋ NSW, សាលាកាតូលិករដ្ឋ NSW និងសមាគមសាលាឯករាជ្យរដ្ឋ NSW។

កម្មវិធីនេះត្រូវបានណែនាំដើម្បីជួយសិស្ស ដែលការរៀនសូត្ររបស់ពួកគេត្រូវបានរងផលប៉ះពាល់ ដោយរយៈពេលអូសបន្លាយពេលនៃការរៀនសូត្រពីផ្ទះជាចម្បង ដោយសារតែជំងឺរាតត្បាត COVID-19។ កម្មវិធីនេះផ្ដោតលើអក្ខរកម្ម និងលេខនព្វន្ត។

សាលារៀននីមួយៗបង្កើតកម្មវិធីរបស់ខ្លួន ដោយផ្អែកលើតម្រូវការរបស់សិស្សពួកគេ ហើយគ្រប់គ្រងកម្មវិធីដែលជួលគ្រូបង្រៀនទទួលការបណ្ដុះបណ្ដាលពិសេស និងអ្នកអប់រំផ្សេងទៀតដូចជា គ្រូបង្រៀនសកលវិទ្យាល័យ និងគ្រូបង្រៀនសាលាត្រៀម។ មេរៀនជាក្រុមតូចទាំងនេះអាចធ្វើឡើងមុន ឬក្រោយសាលា ឬក្នុងអំឡុងម៉ោងសិក្សា។

### របៀបដែលកម្មវិធីដំណើរការ

តាមរយៈកម្មវិធីគាំទ្រការរៀនសូត្រសកម្ម COVID សាលារៀនត្រូវបានផ្ដល់មូលនិធិដើម្បីជួលអ្នកអប់រំបន្ថែម ដែលផ្ដល់ការបង្រៀនអប់រំជាក្រុមតូចសម្រាប់សិស្ស។

ដោយរួមគ្នាជាមួយនាយកសាលា និងការប្រើប្រាស់ការវាយតម្លៃផ្សេងៗគ្នា គ្រូនៅក្នុងថ្នាក់រៀនកំណត់ថាតើកុមារណា នឹងទទួលបានអត្ថប្រយោជន៍ពីការបង្រៀនអប់រំជាក្រុមតូច។

បន្ទាប់មក ការដាក់បញ្ចូលរបស់កុមារម្នាក់ៗនៅក្នុងកម្មវិធី ត្រូវបានពិភាក្សាជាមួយឪពុកម្ដាយ ឬអ្នកថែទាំរបស់ពួកគេ ហើយផែនការបង្រៀនត្រូវបានបង្កើតឡើង។ វឌ្ឍនភាពរបស់កុមារត្រូវបានត្រួតពិនិត្យជាទៀងទាត់ ហើយទំនាក់ទំនងជាមួយឪពុកម្ដាយ និងអ្នកថែទាំត្រូវបានរក្សាទុក។

### លក្ខណៈសំខាន់ៗនៃកម្មវិធី

- សិស្សនៅគ្រប់សាលារៀនរដ្ឋក្នុងរដ្ឋ NSW ធ្លាប់បានគាំទ្រដោយកម្មវិធី។ នៅឆ្នាំ២០២១ សិស្សសរុបចំនួន ២៦៥,០០០នាក់ត្រូវបានគាំទ្រ។
- ការបង្រៀនអប់រំជាក្រុមតូច ត្រូវបានផ្ដល់ដោយអ្នកអប់រំបន្ថែម - រួមទាំងគ្រូបង្រៀនម្ដងម្កាល និងបណ្ដោះអាសន្ន គ្រូបង្រៀនចូលនិវត្តន៍ និងគរុនិស្សិត (និស្សិតហ្វឹកហាត់ធ្វើគ្រូបង្រៀន)។ គ្រូបង្រៀនបន្ថែម ធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្រូនៅក្នុងថ្នាក់រៀន ដើម្បីប្រាកដថាការបង្រៀនអប់រំត្រូវបានកំណត់គោលដៅទៅតាមតម្រូវការរបស់សិស្ស។
- ការបង្រៀនអប់រំផ្ដោតលើអក្ខរកម្ម និងលេខនព្វន្ត។

- ក្រុមអ្នកអប់រំឯកទេស និងអ្នកគ្រប់គ្រង គាំទ្រ និងណែនាំសាលាក្នុងការអនុវត្តកម្មវិធី។
- ការបង្រៀនអប់រំជាក្រុមតូច ពាក់ព័ន្ធនឹងការគាំទ្រលើការបង្រៀន និងការរៀនសូត្របង្គ្រប់បន្ថែមសម្រាប់ក្រុមសិស្ស២-៥នាក់។ សិស្សត្រូវបានបង្រៀនជាប់លាប់ សម្រាប់ចំនួនពេលវេលាដែលបានកំណត់ទុកជាមុន ដោយមានបំណងពង្រឹងការបង្រៀននៅក្នុងថ្នាក់។

### កម្មវិធីគាំទ្រការរៀនសូត្រសកម្ម COVID និងកូនរបស់អ្នក

គ្រូបង្រៀនរបស់កូនអ្នកនឹងទាក់ទងមកអ្នក ប្រសិនបើពួកគេយល់ឃើញថាកម្មវិធីនឹងផ្តល់អត្ថប្រយោជន៍ដល់កូនរបស់អ្នក។

ប្រសិនបើអ្នកចង់ដឹងបន្ថែមអំពីកម្មវិធីនេះ សូមចូលទៅកាន់គេហទំព័រ កម្មវិធីគាំទ្រការរៀនសូត្រសកម្ម COVID (COVID Intensive Learning Support Program webpage)។ ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមពិភាក្សាអំពីកម្មវិធីនេះជាមួយគ្រូបង្រៀនរបស់កូនអ្នក។

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទទៅនាយកសាលារបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទមក សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ សូមប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ ដើម្បីជួយអ្នកក្នុងការសន្ទនា។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។